**NEWS RELEASE**

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# អ្នកជំនាញសិទ្ធិមនុស្ស អ.ស.ប ថ្កោលទោសចំពោះការសម្លាប់អ្នកវិភាគនយោបាយរបស់កម្ពុជា និងជាសកម្មជន លោក កែម ឡី

ទីក្រុងហ្សឺណែវ (១៣ កក្កដា ២០១៦) - ក្រុមអ្នកជំនាញ*សិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅថ្ងៃនេះ បានថ្កោលទោសចំពោះការធ្វើឃាតលើអ្នកវិភាគនយោបាយរបស់កម្ពុជា និងជាសកម្មជនសង្គម លោក កែម ឡី ដែកគេស្គាល់លោកថាជាអ្នកតស៊ូដើម្បីយុត្តិធម៌ និងសិទ្ធិមនុស្សនៅកម្ពុជា។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា "យើងមានការតក់ស្លុតដែលបានដឹងពីការស្លាប់របស់ លោក កែម ឡី។ យើងសូមអំពាវនាវឲ្យមានការស៊ើបអង្កេតមួយឲ្យបានឆាប់រហ័ស ដោយហ្មត់ចត់ និងមិនលំអៀង លើបទល្មើសនេះ ដែលនឹងធានាថាមិនមានជនល្មើសណាម្នាក់រួចផុតពីការផ្តន្ទាទោសឡើយ។ ការស៊ើបអង្កេតនេះគួរតែធ្វើឡើងដោយស្ថាប័នឯករាជមួយដែលមិនមានទំនាក់ទំនងទៅនឹងរដ្ឋាភិបាល"។

លោក កែម ឡី ដែលត្រូវបានបាញ់សម្លាប់នៅក្នុងហាងមួយនៅស្ថានីយ៍ប្រេងមួយកន្លែង កាលពីថ្ងៃទី១០ ខែកក្កដា ធ្លាប់ជាស្ថាបនិកនៃបណ្តាញថ្នាក់មូលដ្ឋានខ្មែរដើម្បីខ្មែរ និងជាអ្នកអត្ថាធិប្បាយពីបញ្ហានយោបាយលេចធ្លោមួយរូប ដែលបានរិះគន់រដ្ឋាភិបាលជាញឹកញយ។ បណ្តាញរបស់លោកនាពេលថ្មីៗនេះបានចុះបញ្ជីជាគណបក្សប្រជាធិបតេយ្យមូលដ្ឋាន ដើម្បីដាក់បេក្ខជនសម្រាប់ការបោះឆ្នោតនៅឆ្នាំ ២០១៧។ មុនលោកចូលប្រឡូកក្នុងការងារដើម្បីប្រជាពលរដ្ឋ លោកមានតួនាទីយ៉ាងសំខាន់ក្នុងវិស័យសុខាភិបាល និងមេរោគអេដស៍រយៈពេលជាច្រើនឆ្នាំ។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា៖ "កាលៈទេសៈនៃការស្លាប់របស់ លោក កែម ឡី បានកាន់តែធ្វើឲ្យមានការព្រួយកង្វល់យ៉ាងខ្លាំង ដោយសារតែជំហររបស់លោកធ្លាប់ជាអ្នករិះគន់រដ្ឋាភិបាល និងមតិយោបល់ជាប្រចាំរបស់លោកក្នុងប្រព័ន្ធផ្សព្វផ្សាយដែលបានគូសបញ្ជាក់ពីកង្វល់ចំពោះអភិបាលកិច្ច និងបញ្ហាសិទ្ធិមនុស្ស"។

ក្រុមអ្នករាយការណ៍ពិសេសបានស្វាគមន៍ចំពោះការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលកម្ពុជាលើការស៊ើបអង្កេតដ៏ហ្មត់ចត់លើបទឧក្រិដ្ឋមួយនេះ និងបានសង្កត់ធ្ងន់ថា ក្រុមគេនឹងធ្វើការតាមដានរឿងនេះយ៉ាងដិតដល់។ ក្រុមអ្នកជំនាញសិទ្ធិមនុស្សរបស់ អ.ស.ប បានសង្កត់ធ្ងន់ថា "បុគ្គលគ្រប់រូបដែលត្រូវទទួលខុសគួរតែនាំយកមកទទួលទោសតាមច្បាប់"។

ក្រុមអ្នកជំនាញខាងសិទ្ធិមនុស្ស អ.ស.ប ក៏បានអំពាវនាវផងដែរដល់រដ្ឋាភិបាលកម្ពុជាឲ្យអនុវត្តជាបន្ទាន់នូវវិធានការការពារប្រកបដោយប្រសិទ្ធភាព ដើម្បីការពារអ្នកដែលធ្វើសកម្មភាពការងារផ្សេងៗដើម្បីប្រជាពលរដ្ឋឲ្យរួចផុតពីឧក្រិដ្ឋកម្មបែបនេះនាពេលអនាគត។

ក្រុមអ្នកជំនាញបានមានប្រសាសន៍ថា៖ "ការបាញ់ប្រហារនេះ ជាឧទាហរណ៍បង្ហាញពីនិន្នាការអវិជ្ជមានកំពុងធ្វើឲ្យមានការព្រួយបារម្ភ នៅក្នុងប្រទេសកម្ពុជា ដែលតាមរយៈនិន្នាការអវិជ្ជមាននេះ យើងឃើញថាសកម្មជននយោបាយ និងអ្នកការពារសិទ្ធិមនុស្ស កំពុងប្រឈមនឹងការរឹតត្បិតកាន់តែខ្លាំងឡើងក្នុងការអនុវត្តសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននានា"។ "អាជ្ញាធរទាំងឡាយត្រូវតែធ្វើសកម្មភាពឲ្យបានឆាប់រហ័សដើម្បីផ្លាស់ប្តូរនិន្នាការអវិជ្ជមាននេះ ដោយហេតុថាការសម្លាប់នេះគឺទំនងជានឹងមានផលបច្ច័យមិនល្អទៅលើកិច្ចខិតខំប្រឹងប្រែងដើម្បីលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា"៕

ចប់

*(*) **លោក មីសែល ហ្វ័ស្ត៍** (Mr. Michel Forst) អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស, លោកស្រី **សាស្ត្រាចារ្យ រ៉ូណា ស្មីត** (Rhona Smith) អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា, **លោក ដេវី កាយេ** (Mr. David Kaye) អ្នករាយការណ៍ពិសេស ស្តីពីសេរីភាពនៃគំនិត និងការសម្តែងមតិ, **លោក ម៉ៃណា គីអាយ** (Mr. Maina Kiai) អ្នករាយការណ៍ពិសេស ស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងបង្កើតសមាគម និង **លោក គ្រីស្តុហ្វ ហៃអ៊ីន** (Mr. Christof Heyns) អ្នករាយការណ៍ពិសេស ស្តីពីការសម្លាប់ភ្លាមៗតាមទំនើងចិត្ត គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស ដែលជាស្ថាប័នធំបំផុតមួយរបស់អ្នកជំនាញការឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប គឺជាឈ្មោះទូទៅនៃយន្តការឃ្លាំមើល និងស្វែងរកការពិតដោយឯករាជ្យរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលដោះស្រាយស្ថានភាពជាក់លាក់នៃប្រទេសនីមួយៗ ឬបញ្ហាតាមវិស័យមួយៗនៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ អ្នកជំនាញការនៃនីតិវិធីពិសេស ធ្វើការផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត គាត់មិនមែនជាបុគ្គលិករបស់ អ.ស.ប ទេ ហើយមិនទទួលប្រាក់បៀវត្សន៍ពីការងាររបស់ខ្លួន។ គាត់ធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលគាត់ផ្ទាល់។*

**ដើម្បីស្វែងយល់បន្ថែម សូមចូលទៅកាន់៖**

**អ្នកការពារសិទ្ធិមនុស្ស៖**

*http://www.ohchr.org/EN/Issues/SRHRDefenders/Pages/SRHRDefendersIndex.aspx*

**សិទ្ធិមនុស្សនៅកម្ពុជា៖**

*http://www.ohchr.org/EN/HRBodies/SP/CountriesMandates/KH/Pages/SRCambodia.aspx*

**សេរីភាពនៃការសម្តែងមតិ៖**

*http://www.ohchr.org/EN/Issues/FreedomOpinion/Pages/OpinionIndex.aspx*

**សេរីភាពក្នុងការជួបប្រជុំ និងសិទ្ធិសេរីភាពក្នុងបង្កើតសមាគម៖**

*http://www.ohchr.org/EN/Issues/AssemblyAssociation/Pages/SRFreedomAssemblyAssociationIndex.aspx*

**ការសម្លាប់ភ្លាមៗ៖** *http://www.ohchr.org/EN/Issues/Executions/Pages/SRExecutionsIndex.aspx*

*សិទ្ធិមនុស្ស អស.ប. គេហទំព័រប្រទេស – កម្ពុជា៖*
*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទងមក លោក ធីបូត ហ្គីលឡេ (Mr. Thibaut Guillet) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៦ ៧៤/ អ៊ីម៉ែល៖ អ៊ីម៉ែល)*

**សម្រាប់វិបសាយព័ត៌មាននិងបណ្ដាញសង្គមរបស់អ្នក៖** មាតិកាពហុព័ត៌មាន និងសារគន្លឹះៗទាក់ទងនឹងសេចក្តីប្រកាសព័ត៌មានរបស់យើង អាចរកបាននៅលើឆាណែលបណ្ដាញសង្គមសិទ្ធិមនុស្ស អ.ស.ប ដូចមានរាយឈ្មោះខាងក្រោម។ សូមថេក (tag) មកយើងដោយប្រើចំណុចទាញត្រឹមត្រូវ៖

**ទ្វីតធឺ៖** @UNHumanRights

**ហ្វេសប៊ុក៖**: unitednationshumanrights

**អ៊ីនស្តាហ្គ្រាម៖** unitednationshumanrights

**ហ្គោហ្គីល៖** Google+: unitednationshumanrights

**យូធូប៖** unohchr